# សវនាការលើភ័ស្តុតាងក្នុងសំណុំរឿង០០២ ចាប់ផ្តើមដោយការសួរសំណួរទៅ នួន ជា

**ដោយ គ្រីសស៊ីន អ៊ីវេន**

**ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១**

*ប្រែសម្រួលដោយ ដា ផល្លា*

ថ្ងៃនេះ សវនាការលើភ័ស្តុតាងក្នុងសំណុំរឿង០០២ចាប់ផ្តើម ហើយ នួន ជា បានត្រលប់ទៅកាន់ទីក្រុចកសេះវិញ ។ សវនាការថ្ងៃទីមួយនេះប្រកបទៅដោយការរំខានជាច្រើនលើកច្រើនសារដោយសារតែបញ្ហានិតិវិធីផ្សេងៗ ហើយទីបញ្ចប់ត្រូវបានបន្ផ្អាក់ម្តងទៀតដោយសារតែស្ថានភាពសុខភាពរបស់ នួន ជា ។

អារម្មណ៍របស់អ្នកចូលរួមស៊ីគ្នាទៅនិងដំណើរការនិតិវិធីរបស់តុលាការដែរ ។ អ្នកចូលរួមមានសភាពស្ងប់ស្ងាត់ស្ទើរតែពេញមួយព្រឹក ហើយគ្រាន់តែអង្គសវនាការចាប់ផ្តើមកិច្ចការនិតិវិធី និស្សិតជាច្រើនចាប់ផ្តើមបិតភ្នែកសម្ងំគេង តែអ្នកទាំងនោះត្រូវបានសន្តិសុខរំពៃមើលយ៉ាងយកចិត្តទុកដាក់ ជាពិសេសពេលដែលតុលាការចាប់ផ្តើមអានដីការដំណោះស្រាយ ។ គ្រាន់តែ នួន ជា ចូលដល់ទីក្រុចកសេះភ្លាម អ្នកចូលរួមចាប់ផ្តើមស្ទុះស្ទាភ្លាមដែរ ។ ពេលនោះភាគីដើមបណ្តឹងរដ្ឋប្បវេណីចាប់ផ្តើមបង្ហាញពីគំនិតយោបល់របស់ខ្លួនតាមរយៈការនិយាយគ្នាលឺៗទៅកាន់អ្នកអង្គុយជិតខ្លួន ហើយអ្នកទាំងនោះបានគ្រវីក្បាល រហូត ពេលដែល នួន ជា កំពុងឆ្លើយសំនួរទៅចៅក្រម ។

## ទម្រង់ការនិតិវិធី

បុរេជំនុំជម្រះចាប់ផ្តើមកិច្ចការរបស់ខ្លួនដោយការបញ្ចប់កិច្ចការនិតិវិធីមួយចំនួន ។ បន្ទាប់ពីចៅក្រមបង្គាប់ឲ្យចាប់ផ្តើមកិច្ចការបន្តទៀត ក្រឡាបញ្ជីបានឡើងរាយការណ៍អំពីវត្តមានរបស់ភាគីទាំងអស់ដោយបញ្ជាក់ពីការអវត្តមានរបស់មេធាវីការពារក្តីអន្តរជាតិពីររូប ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនាំមុខបានឡើងណែនាំខ្លួនមេធាវីដើមបណ្តឹងរដ្ឋប្បវេណីថ្មី ដែលត្រូវបានទទួលស្គាល់ដោយតុលាការរួចហើយ ។ ប្រធានចៅក្រម និល ណុន ក៏បានបញ្ជាក់ដែរថា មេធាវីអន្តរជាតិរបស់ នួន ជា ឈ្មោះ អេនទ្រូ អៀនូហ្ស៊ី ត្រូវបានទទួលស្គាល់ជាលាយលក្ខណ៍អក្សរដោយតុលាការរួចហើយកាលពីសប្តាហ៍មុន ។

ក្រោយមក មេធាវី អៀនូហ្ស៊ី បានក្រោកឈរ និងឡើងថ្លែងទៅកាន់តុលាការដោយស្នើរសុំពេលធ្វើសេចក្តីថ្លែងការណ៍អំពីបញ្ហាបឋមមួយចំនួនមុននិងដំណើរការតុលាការចាប់ផ្តើម ។ ដោយសារតែប្រធាន និល ណុន មិនបានឆ្លើយតប មេធាវី អៀនូហ្ស៊ី បានស្នើរទៅកាន់តុលាការមួយទៀត ។

ទីបញ្ចប់ និល ណុន បានឆ្លើយតបដោយបញ្ជាក់ថា អង្គសវនាការនឹងបញ្ចប់កិច្ចការនីតិវិធីដែលបាន ចាប់ផ្តើមរួចហើយមុននឹងធ្វើការដោះស្រាយទៅនឹងសំណើររបស់ភាគីការពារក្តី ។

មេធាវី អៀនូហ្ស៊ី បានបញ្ជាក់ឡើងវិញថា សេចក្តីថ្លែងរបស់ខ្លួនគឺសំដៅទៅនឹងការអាននៃផ្នែក ខ្លះដែលពាក់ព័ន្ធគ្នានៃបទពិរុទ្ធ ហើយខ្លួនចង់មានមតិខ្លះមុននឹងបទពិរុទ្ធនោះត្រូវបានអាន ។ ក្រោយមក ចៅក្រម និល ណុន បានបង្គាប់ឲ្យមេធាវី អៀនូហ្ស៊ី អង្គុយ ហើយបានជម្រាបទៅមេធាវីនោះថា តុលាការបានធ្វើសេចក្តីសម្រេចរួចហើយ ហើយថា មេធាវីនឹងមានពេលនិយាយនៅពេលដែលមាន ការបកស្រាយទាក់ទងទៅនឹងករណី នួន ជា ។

**ភាពលំដាប់លំដោយនៃសវនាការលើភស្តុតាង**

យោងតាមសេចក្តីបង្គាប់របស់អង្គជំនុំជម្រះកាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ចៅក្រម និល ណុន បានធ្វើការរំលឹកទៅភាគីទាំងអស់ថា ដំណាក់កាលតំបូងរបស់សវនាការនេះនឹងនិយាយទាក់ ទងតែនឹង ១) ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា និង២) ប្រវត្តិរបស់ជនជាប់ចោទមុនរបបកម្ពុជាប្រជាធិប តេយ្យប៉ុណ្ណោះ ។ ភស្តុងតាងដែលនឹងត្រូវយកមកបង្ហាញអំឡុងពេលដំណាក់កាលតំបូងនេះនឹងកំណត់ ត្រឹមតែហេតុការណ៍ដែលបានចោទប្រកាន់មកលើជនជាប់ចោទតែប៉ុណ្ណោះ នៅក្នុងកថាខណ្ឌនៃដីការ ដំណោះស្រាយកាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ប៉ុណ្ណោះ ។

បន្ទាប់មក ចៅក្រម និល ណុន បានបញ្ជាក់ថា សវនាការលើភស្តុតាងនឹងចាប់ផ្តើមដោយការ សួរសំណួរទៅកាន់ជនជាប់ចោទ ដែលចាប់ផ្តើមពី នួន ជា មុន ។ លំដាប់លំដោយនៃសំនួរមានដូច ខាងក្រោម :

១. ប្រធានអង្គជំនុំជម្រះ

២. ចៅក្រមណាមួយដែលចាត់តាំងដោយប្រធានអង្គជំនុំជម្រះ

៣. ចៅក្រមផ្សេងទៀតដែលមានបំណងចង់សួរសំនួរទៅជនជាប់ចោទ

៤. សហព្រះរាជអាជ្ញា

៥. ដើមបណ្តឹងរដ្ឋប្បវេណី និង

៦. មេធាវីរបស់ជនជាប់ចោទម្នាក់ៗ ។

ការសួរសំនួរទៅកាន់ជនជាប់ចោទត្រូវរំពឹងថានឹងបញ្ចប់នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ ហើយ តុលាការនឹងចាប់ផ្តើមដំណើរការសវនាការឡើងវិញ ជាមួយនឹងការធ្វើសក្ខីកម្មរបស់ភាគីដើមបណ្តឹងរដ្ឋ ប្បវេណីនិងអ្នកជំនាញនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ខាងមុខនេះ ។ ចៅក្រម និល ណុន បាន បញ្ជាក់ឲ្យច្បាស់ឡើងវិញថា ទោះបីជាមានការបង្អាក់នៅក្នុងដំណើរការនេះក៏ដោយ ក៏សាក្សីភាគីដើម

បណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានជម្រាបនៅក្នុងដំណាក់កាលតុលាការនេះរួចហើយអាចនឹងផ្តល់សក្ខីកម្មរាល់បញ្ហាទាំងអស់បានដែលអ្នកទាំងនោះធ្លាប់ដឹង និងធ្លាប់ឆ្លងកាត់ ហើយតុលាការនឹងមិនជូនដំណឹងម្តងទៀតទេនៅពេលក្រោយ ។ អង្គសវនាការក៏បានអះអាងផងដែរថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីណាដែលមានបំណងចង់ធ្វើសក្ខីកម្ម គួរតែបញ្ជាក់ពីផលប៉ះពាល់មកលើខ្លួនឲ្យចំចំណុចដែលខ្លួនធ្លាប់ទទួលរង ។

ចៅក្រម និល ណុន បានផ្តល់ឈ្មោះក្លែងក្លាយរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីពីររូប និងសាក្សីបួនរូបដែលរំពឹងថានឹងចូលខ្លួនមកផ្តល់សក្ខីកម្ម ហើយចៅក្រមបានបញ្ជាក់ឲ្យច្បាស់ម្តងទៀតថា សាក្សីនឹងមិនត្រូវប្រាប់ឈ្មោះពិតទេរហូតដល់សាក្សីនោះបានចូលខ្លួនក្នុងសវនាការតែម្តង ។

ទីបញ្ចប់ ចៅក្រម និល ណុន បានរំលឹកទៅមេធាវីទាំងអស់ថា ការជំទាស់មិនឲ្យមានការធ្វើសក្ខីកម្មអាចធ្វើបាន ដោយអនុលោមតាមវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងក្រមនិតិវិធីព្រហ្មទណ្ឌកម្ពុជា ។ ចៅក្រម និល ណុន ក៏បានបញ្ជាក់ដែរថា អង្គសវនាការរំពឹងថា ភាគីមេធាវីនឹងគោរពនូវគោលការណ៍នេះឲ្យស្របតាមបទដ្ឋានវិជ្ជាជីវៈក្នុងការសួរសំនួរ ហើយថា សកម្មភាពនិងអកប្បកិរិយា និងការប្រើភាសាមិនគប្បីណាមួយនឹងមិនអាចយោគយល់បានឡើយ ។

## ការអានដីការដំណោះស្រាយ

ដោយសារដំណើរការនិតិវិធីចប់សព្វគ្រប់ហើយ ចៅក្រម និល ណុន បន្តាប់ទៅក្រឡាបញ្ជីរបស់តុលាការអានហេតុការណ៍ និងបទចោទប្រកាន់ទាក់ទងទៅនឹងដំណាក់កាលតំបូងរបស់សវនាការ ។ ទាកទងទៅនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ក្រឡាបញ្ជីបានអានកថាខណ្ឌពី១៨ដល់៣២ របស់ដីការដំណោះស្រាយកាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ។ កថាខណ្ឌទាំងនេះបកស្រាយអំពីហេតុការណ៍ទាក់ទងនឹងការដុះដាលនិងសកម្មភាពរបស់បក្សកុម្មុយនីស្តនៅប្រទេសកម្ពុជាចាប់ពីទសវត្សរ៍៥០ រហូតដល់ដើមទសវត្សរ៍៧០ និងសម័យកាលមុនរបបកម្ពុជាប្រជាធិបតេយ្យ ។

បន្ទាប់មក ក្រឡាបញ្ជីម្នាក់ទៀតបានឡើងអានកថាខណ្ឌនៃដីកាដំណោះស្រាយដែលទាក់ទងទៅនឹងប្រវត្តិរបស់ជនជាប់ចោទនីមួយៗក្នុងការបង្កើតកម្ពុជាប្រជាធិបតេយ្យ ។ កថាខណ្ឌដែលពាក់ព័ន្ធរួមមាន :

- នួន ជា : កថាខណ្ឌទី៨៦២ ដល់ ៨៦៨ និង កថាខណ្ឌទី១៥៧៧ ដល់ ១៥៨០
- អៀង សារី : កថាខណ្ឌទី៩៩៤ ដល់ ១០០០ កថាខណ្ឌ១០៩១ និងកថាខណ្ឌទី១៥៨៥ ដល់ ១៥៨៨ និង
- ខៀវ សំផន : កថាខណ្ឌទី២០២៦ ដល់១០៣០ និងកថាខណ្ឌទី១៥៩៨ ដល់ ១៦០០

កថាខណ្ឌទាំងនេះពិភាក្សាអំពីសមាជិកភាពរបស់ជនជាប់ចោទម្នាក់ៗ នៅក្នុងបក្សកុម្មុយនីស្ត និងសកម្មនយោបាយមុនឆ្នាំ១៩៧០ និងប្រវត្តិគ្រួសារនិងការអប់រំរបស់ជនជាប់ចោទ ។ ការអានព័ត៌មាននេះ បង្កឲ្យមានការប្រតិកម្មមួយចំនួនពីភាគីដើមបណ្ដឹងរដ្ឋប្បវេណីដែលអង្គុយនិងក្នុងបន្ទប់សម្រាប់អ្នកចូលរួម ។ ការអានអំពីហេតុការណ៍ដែលថាឪពុករបស់ អៀង សារី គឺជាខ្មែរក្រោម និងម្ដាយរបស់ខ្លួនជាកូនកាត់ចិន-វៀតណាម មើលទៅហាក់បីដូចជាមានការចាប់អារម្មណ៍ជាច្រើនពីសំណាក់អ្នកចូលរួម ហើយក៏បង្កឲ្យមានការពិភាក្សាច្រើនដែរពីសំណាក់អ្នកតាមដានដំណើរការទាំងអស់ ។

បន្ទាប់ពីការអានដីការដំណោះស្រាយរួចមក ចៅក្រម និល ណុន បានសួរទៅព្រះរាជអាជ្ញាថាតើយល់ព្រមទៅនិងហេតុការណ៍ដែលបានរៀបរាប់នោះដែរឬយ៉ាងណា ។ សហព្រះរាជអាជ្ញារងបានឆ្លើយតបថា គ្មានហេតុការណ៍ណាមួយដែលយល់ស្របទេ ។ ចៅក្រម ខាត់ វ្រាយត៏ បាននាំចំណាប់អារម្មណ៍តុលាការដោយបង្ហាញនូវអនុស្សារណៈដែលបានដាក់ជូនថ្មីៗដោយ អៀង សារី ដែលនៅក្នុងអនុស្សារណៈនោះបានរៀបរាប់ពីហេតុការណ៍ពិតតិចតួចប៉ុណ្ណោះ ។

ម៉ៃឃើល ខាណាវ៉ាស បានឆ្លើយតបតំណាងឲ្យក្រុមរបស់ អៀង សារី ដោយបញ្ជាក់ថាខ្លួនបានឆ្លើយតបទៅនិងសំណើរបស់ព្រះរាជអាជ្ញារួចហើយដោយកិច្ចព្រមព្រៀង«សមញ្ញ» ដែលភាគច្រើនទាក់ទងទៅនិងប្រវត្តិរបស់ជនជាប់ចោទម្នាក់ៗ ។ ម៉ៃឃើល ខាណាវ៉ាស បានបញ្ជាក់ថា ខ្លួនមានឆន្ទះនិងពិភាក្សាអំពីហេតុការណ៍ទាំងនេះជាមួយព្រះរាជអាជ្ញា ហើយក៏បានរាយការណ៍ទៅតុលាការវិញរួចហើយ តែ ម៉ៃឃើល ខាណាវ៉ាស បានអះអាងទៀងថា បញ្ហាទាំងនេះមិនគួរត្រូវបានពន្យាពេលទេសម្រាប់ដំណើរការថ្ងៃនេះ ។ ចៅក្រម និល ណុន បានយល់ស្របដោយបញ្ជាក់ថា បញ្ហានេះនិងយកមកពិភាក្សាម្ដងទៀតនៅចំពោះមុខតុលាការពេលដែលមានការសួរសំនួរទៅកាន់ អៀង សារី ។

## បញ្ហានិតិវិធីផ្សេងទៀត

មុននិងចាប់ផ្ដើមសួរសំនួរទៅកាន់ជនជាប់ចោទ អង្គសវនាការបានងាកទៅរកក្រុមការពារក្ដីរបស់ នួន ជា ដើម្បីបញ្ចប់បញ្ហាបឋមមួយចំនួនដែល និល ណុន បានលើកមកពិភាក្សាពីមុន ។ មេធាវី អៀនូហ្ស៊ី បានទាញចំណាប់អារម្មណ៍ដោយពិភាក្សាអំពីអនុស្សារណៈរបស់មន្ត្រីជាន់ខ្ពស់អង្គជំនុំជម្រះដែលបានបញ្ជាក់ថា ឯកសារនិងសេចក្ដីថ្លែងការណ៍របស់សាក្សីមានលេខយោងជាច្រើននៃដីការដំណោះស្រាយដែលនិងជាផ្នែកមួយនៃឯកសារសំណុំរឿង ។ និល ណុន បានបញ្ជាក់សារឡើងវិញអំពីការបដិសេធរបស់ នួន ជា ជាពិសេសទាក់ទងទៅនិងការបញ្ចូលឈ្មោះសាក្សីនៅក្នុងបញ្ជី ដែលនិងមិនមកធ្វើសក្ខីកម្មនៅក្នុងដំណើរការសវនាការ ។

មេធាវី អៀនូហ្ស៊ី ក៏បានសំអាងទៅរកអនុស្សារណៈពីសហព្រះរាជអាជ្ញាដែលក្នុងនោះសហព្រះរាជអាជ្ញាបានផ្ដល់ “Indicia of Reliability” ចំពោះឯកសារនិងសេចក្ដីថ្លែងការណ៍របស់សាក្សីដែលនិងយកមកនិយាយអំឡុងពេលដំណើរការសវនាការ ។ មេធាវី អៀនូហ្ស៊ី ស្វាគមន៍ដល់ព្រះរាជអាជ្ញាចំពោះការងារនេះ ហើយក្រោយមក គាត់បានស្នើរទៅតុលាការឲ្យពិចារណាក្នុងការធ្វើកិច្ចការនេះជាមួយនិងភស្តុតាងដែលនិងបញ្ចូលក្នុងសំណុំឯកសារ ។

ទីបញ្ចប់ មេធាវី អៀនូហ្ស៊ី បានយកបញ្ហាទាក់ទងនិងអនុស្សារណៈថ្មីៗរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ម្នាក់ដែលបញ្ជាក់ថា សាក្សីនិងទទួលបានការអនុញ្ញាតិឲ្យអានសេចក្ដីថ្លែងការណ៍មុននិងឡើងធ្វើសក្ខីកម្មនៅចំពោះមុខតុលាការ ។ ការធ្វើបែបនេះគឺដើម្បីឲ្យការចងចាំកាន់តែច្បាស់ជាងមុន ។ មេធាវី អៀនូហ្ស៊ី បានរំលឹកទៅតុលាការម្ដងទៀតថា ក្រុមរបស់ នួន ជា បានធ្វើការជំទាស់ជាច្រើនលើកច្រើនសាររួចមកហើយចំពោះបញ្ហានេះ ហើយបាននិយាយថា ខ្លួនមិនទាន់ទទួលបាននូវអ្វីដែលខ្លួនចាត់ទុកថាជាការសម្រេចចិត្ត“សមហេតុផល”នៅឡើយទេទាក់ទងនិងបញ្ហានេះ ។ មេធាវី អៀនូហ្ស៊ី បានស្នើរទៅតុលាការឲ្យបន្តពិនិត្យមើលសាក្សីទាំងនោះទៀតរហូតដល់ការសម្រេចចិត្ត ដ៏សមហេតុផលមួយត្រូវបានធ្វើឡើង ។

អាង ឧត្តម មេធាវីរបស់ អៀង សារី ក៏បានលើកឡើងពីបញ្ហាបឋមមួយដែលខុសពីអ្វីដែលបានលើកឡើងដោយ មេធាវី អៀនូហ្ស៊ី ។ អាង ឧត្ដម បានលើកឡើងថា តាមច្បាប់នៅក្នុងតុលាការជាតិគឺ មិនបញ្ចូលសាក្សីនិងភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងដំណើរការសវនាការទេ ហើយពេលនោះ អាង ឧត្ដម បានស្នើរទៅតុលាការឲ្យពិចារណាសំណើរនេះ ។

និល ណុន បានឆ្លើយតបទៅកាន់មេធាវី អាង ឧត្តម និង មេធាវី អៀនូហ្ស៊ី ដោយបញ្ជាក់ថា សំណើនេះនិងយកមកពិចារណា ហើយថា តុលាការនិងធ្វើការសម្រេចឲ្យបានឆាប់ ។ និល ណុន បានបញ្ជាក់ទៅ អាង ឧត្ដម ថា ធម្មជាតិ “វិសាមញ្ញ” របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានន័យថា អង្គសវនាការមិនអាចយកច្បាប់ជាតិមកអនុវត្តិទាំងស្រុងទេ ។ អាង ឧត្ដម បានការពារការអនុវត្តិច្បាប់របស់តុលាការនេះដោយអះអាងថា តុលាការខ្មែរក្រហមនេះមានការប្រុងប្រយ័ត្នក្នុងការការពារការសម្ងាត់នៅក្នុងដំណើរការសវនាការឲ្យបានច្រើនបំផុតតាមតែអាចធ្វើទៅបាន ដើម្បីឲ្យសាធារណជនដឹងឲ្យបានច្រើនពីធម្មជាតិរបស់តុលាការខ្មែរក្រហមនេះ ។

មុននិងឈប់សម្រាកនៅពេលព្រឹក សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនាំមុខ អេលីហ្សាបេិត ស៊ីម៉ូណូ ហ្វុត បានស្នើរថា តុលាការគួរតែចាំក្នុងការធ្វើសេចក្ដីសម្រេចអំពីបញ្ហានេះថា ច្បាប់កម្ពុជា

និងច្បាប់ស៊ីវិលគឺមានភាពខុសគ្នារវាងដើមបណ្តឹងរដ្ឋប្បវេណីនិងសាក្សី ។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីគឺមានសិទ្ធ និងចូលរួមរាល់ដំណើរការសវនាការទាំងអស់ ទោះបីជាមិនបានធ្វើសក្ខីកម្មក៏ដោយ ។

## **ការចោទសួរចាប់ផ្តើម ៖ នួន ជា**

ភ្លាមៗក្រោយពីអង្គសវនាការចាប់ផ្តើមក្រោយពីសម្រាកនៅពេលព្រឹក ចៅក្រម និល ណុន បានបង្គាប់ទៅសន្តិសុខឲ្យនាំជនជាប់ចោទ នួន ជា ចូលមកកាន់ទីក្រចកសេះដើម្បីចាប់ផ្តើមសួរសំនួរ ។ សាធារណជនហាក់មានអារម្មណ៍រស់រវើកឡើងនៅពេលដែល នួន ជា ត្រូវបាននាំខ្លួនទៅកាន់ទីក្រចកសេះ ដោយមានជំនួយពីសន្តិសុខពីរនាក់ ។ មនុស្សមួយចំនួនបានសង្កេតឃើញថា នួន ជា ហាក់បីដូចជាមានសុខភាពខ្សោយ ។

មុននិងការសួរសំនួរទៅកាន់ នួន ជា ចាប់ផ្តើម មេធាវីម្នាក់របស់ នួន ជា បានឡើងអះអាងទៅតុលាការទាក់ទងទៅនិងការបាត់ពាក្យមួយចំនួនដែលមិនបានអាននៅក្នុងដីការដំណោះស្រាយ ។ ជាពិសេសមេធាវីរបស់ អៀង សារី បានបញ្ជាក់ថា ក្រឡាបញ្ជីមិនបានអានអក្សរកាត់ “FUNK” ដែលមានន័យថា រណសិរ្សប្រួបប្រួមជាតិកម្ពុជាទេ និងអក្សរកាត់ “GRUNK” ដែលមានន័យថា រាជរដ្ឋាភិបាលរណសិរ្ស បង្រួបបង្រួមជាតិកម្ពុជាទេ ។ មេធាវីរបស់ អៀង សារី ក៏បានគូសបញ្ជាក់ដែរថា ក្រឡាបញ្ជីមិនបានអានព្រះនាមនរោត្តម សីហនុ ឲ្យបានលឺទេនៅក្នុងកថាខណ្ឌទី២៥ និង២៧ ។

និល ណុន បានឆ្លើយតបថា អក្សរកាត់មិនត្រូវបានអានទេដោយសារតែពាក្យនេះមិនមានអត្តន័យទេជាភាសាខ្មែរ ហើយតុលាការមិនចង់ឲ្យសាធារណជនមានការភាន់ច្រឡំនៅពេលដែលដីការដំណោះស្រាយត្រូវបានអានជាភាសាខ្មែរ ។ ចំពោះរឿងដែលមិនបានអានឈ្មោះ និល ណុន បានបញ្ជាក់ថា តុលាការបានឲ្យក្រឡាបញ្ជីអានដីការដំណោះស្រាយដែលបានផ្សាយជាសាធារណៈរួចហើយ ដែលរៀបរាប់ពីឈ្មោះសាក្សីដែលនឹងចូលខ្លួនមកបង្ហាញ ហើយ និល ណុន បានណែនាំឲ្យមេធាវីរូបនោះមើលឡើងនូវអ្វីដែលបានដាក់នៅលើគេហទំព័ររួចហើយ ។

ក្រោយមក និល ណុន បានត្រលប់មករកបញ្ហា នួន ជា វិញ ហើយចាប់ផ្តើមសួរនាំទៅកាន់ជនជាប់ចោទ ។ ដោយសួរពីប្រវត្តិរូបផ្ទាល់ខ្លួន នួន ជា បានឆ្លើយថា ឈ្មោះដើមរបស់គាត់គឺ ឡាវ គីមលន ហើយ«ឈ្មោះបដិវត្តន៍»គឺ នួន ជា ។ គាត់កើតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩២៦ នៅភូមិវត្តគរ ក្នុងខេត្តបាត់ដំបង ។ នួន ជា បានបញ្ជាក់ទៀតថា ឪពុកម្តាយរបស់គាត់គឺ «ខ្មែរសុទ្ធ» ។ គាត់ជាកូនទីបីនៅគ្រួសារ ហើយមានបងប្អូនតែបីនាក់ប៉ុណ្ណោះដែលនៅរស់ ។ គាត់រៀបរាប់ជាមួយប្រពន្ធឈ្មោះ លី គីមសេង ។

ទាក់ទងនៅនឹងកម្រិតវប្បធម៌ នួន ជា បានរៀបរាប់ថា គាត់ចាប់ផ្ដើមចូលរៀននៅអាយុប្រាំពីរឆ្នាំក្នុងសម័យ«អាណានិគមនិយមបារាំង» ។ គាត់ចូលរៀនថ្នាក់មធ្យមសិក្សានៅសាលាលីសេក្នុងខេត្តបាត់ដំបងនៅពេលខេត្តនេះត្រូវបាន«ប្រគល់ជូនទៅប្រទេសថៃ»ក្នុងឆ្នាំ១៩៤១ ហើយពេលនោះគាត់ចាប់ផ្ដើម ទៅរៀននៅប្រទេសថៃ។ ពេលនៅប្រទេសថៃ នួន ជា ក៏ធ្វើការដែរ ដំបូងនៅក្រសួងហិរញ្ញវត្ថុ ហើយក្រោយមកនៅក្រសួងការបរទេស ។ នៅពេលនោះហើយដែលគាត់បានលឺដំណឹងថាបារាំងបានកាប់សម្លាប់ធ្វើបាបខ្មែរ ដូច្នេះគាត់«ចាប់ផ្ដើមតស៊ូ» ។

ក្រោយមក និល ណុន បានជូនដំណឹងទៅ នួន ជា អំពីសិទ្ធនៅក្នុងអង្គសវនាការដោយបញ្ជាក់ថា នួន ជា មានសិទ្ធនិងត្រូវការពារដោយមេធាវីរបស់ខ្លួនតាមតែខ្លួនពេញចិត្តនៅពេលណាក៏បាន។ នៅពេលនេះ នួន ជា ត្រូវបានការពារដោយមេធាវីអន្តរជាតិបីនាក់ និងមេធាវីជាតិម្នាក់ ហើយមេធាវីទាំងបួននេះ ត្រូវបានតំណាងអំឡុងពេលដំណាក់កាលការស៊ើបអង្កេត និងអំឡុងពេលអង្គបុរេជំនុំជម្រះ។ និល ណុន ក៏ បានបញ្ជាក់ផងដែរថា នួន ជា មានសិទ្ធនៅស្ងៀមមិននិយាយស្ដី មានសិទ្ធនិងមិននិយាយស្ដីដែលអាចនិងដាក់បន្ទុកលើខ្លួនឯងនិងមានសិទ្ធក្នុងការទទួលដំណឹងអំពីបទចោទប្រកាន់មកលើខ្លួន ។

នៅពេលសួរថាតើយល់ពីបទចោទប្រកាន់មកលើខ្លួនដែរឬទេ នួន ជា បានបញ្ជាក់ថា គាត់បានអានឯកសារខ្លះ ហើយគាត់ត្រូវបានចោទពីបទឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ និង«បទល្មើសផ្សេងទៀតដែលខ្ញុំមិនចាំ» ដែលប្រហែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

ក្រោយមក ចៅក្រម និល ណុន បានអានបទចោទប្រកាន់មកលើ នួន ជា ដូចដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយរួចហើយដូចជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាពិសេសអំពើមនុស្សឃាតការ សម្លាប់ និងដាក់ជាទាសករ និងផ្លាស់ប្ដូរទីលំនៅដោយបង្ខំ ការដាក់ឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញលើជនដែលមាននិន្នាការនយោបាយ ពូជសាសន៍ និងសាសនាផ្សេងៗ និងសកម្មភាពអមនុស្សធម៌ផ្សេងទៀត អំពើប្រល័យពូជសាសន៍ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវក្នុងឆ្នាំ១៩៤៩ ។ ចៅក្រម និល ណុន បានបញ្ជាក់ដែរថា អង្គបុរេជំនុំជម្រះបានបញ្ចូលបទរំលោភក្រោម «សកម្មភាពអមនុស្សធម៌ផ្សេងៗ» ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ និល ណុន បានបញ្ជាក់ទៀតថា នួន ជា ត្រូវបានជូនដំណឹងជាច្រើនលើកច្រើនសារហើយអំពីបទចោទប្រកាន់នេះដោយផ្ទាល់និងជាលាយលក្ខអក្សរ និងតាមរយៈមេធាវី ហើយ នួន ជា ក៏ត្រូវបានផ្ដល់ឱកាសឲ្យប្ដឹងទៅឧទ្ធរណ៍ដែរ ។

នួន ជា បានឆ្លើយតប ហើយស្នើរទៅអង្គសវនាការថា ខ្លួនសុំឱកាសនិងធ្វើសេចក្តីថ្លែងការណ៍អំពី«ប្រវត្តិតស៊ូ»ដើម្បីរំដោះជាតិ។ នៅក្នុងសេចក្តីថ្លែងការណ៍នោះ នួន ជា បានបញ្ជាក់សាជាថ្មីហើយនិយាយច្រើនជាងកាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ កន្លងទៅពេលដែលគាត់ឡើងឆ្លើយតបទៅកាន់សហព្រះរាជអាជ្ញា។

នួន ជា បានបញ្ជាក់ថា ក្តីប្រាថ្នារបស់ខ្លួនក្នុងការតស៊ូគឺដោយសារតែកាលនោះគាត់បានឃើញដោយផ្ទាល់ភ្នែកនូវការធ្វើបាបមកលើប្រជាជនកម្ពុជាដោយបារាំង និងដោយអ្នកមានអំណាចសម័យអាណានិគមនិយមបារាំង។ នួន ជា បានអះអាងផងដែរថា គាត់បានឃើញដោយផ្ទាល់ភ្នែកនូវប្រជាជនកម្ពុជាដែលត្រូវបានធ្វើបាប វាយដំ និងដាក់ឃុំឃាំងដូចទាសករ។ ដោយសារបញ្ហានេះហើយបានជាគាត់ចូលក្នុងចលនាតស៊ូ ហើយគាត់បាននិយាយថា «ក្តីស្រលាញ់យុត្តិធម៌បានដក់ក្នុងចិត្តខ្ញុំជានិច្ច»។

បន្ទាប់ពីខេត្តបាត់ដំបងត្រូវបានប្រគល់ជូនទៅប្រទេសថៃ នួន ជា សម្រេចចិត្តនិងស្នាក់នៅទីនោះ ដើម្បីសិក្សាដោយសារតែ«ចង់ដឹងថាតើប្រទេសឯករាជ្យមានសភាពយ៉ាងដូចម្តេច»។ គាត់បានទៅរៀនដោយស្នាក់នៅវត្តព្រោះតែឪពុកម្តាយក្រ ហើយឪពុករកស៊ីខាតផង។ ពេលនោះទើប នួន ជា ដឹងថា ប្រទេសថៃគឺមិនឯករាជ្យដូចអ្វីដែលខ្លួនគិតទេ។ ប្រទេសថៃ ដូចប្រទេសកម្ពុជាដែរត្រង់ថា «អ្នកមានគាបសង្កត់អ្នកក្រ» ហើយប្រទេសថៃត្រូវគ្រប់គ្រងដោយចិន។ នួន ជា បានអះអាងថា «ភាពអយុត្តិធម៌មាននៅគ្រប់ទីកន្លែងទាំងអស់»។

នៅពេលនោះ នួន ជា ចាប់ផ្តើមអានសារព័ត៌មានកុម្មុយនីស្តកម្ពុជា និងចាប់ផ្តើមមើលឃើញពីមនោគមន៍វិជ្ជាកុម្មុយនីស្តថាជាវិធីមួយដើម្បីរំដោះប្រទេសជាតិ។ គាត់ចាប់ផ្តើមរៀនពីលទ្ធិកុម្មុយនីស្តពីមិត្តភ័ក្រ្តដែលជាជនជាតិថៃ និងពីសាស្រ្តាចារ្យ «ចម្រើន» នៅសាកលវិទ្យាល័យរបស់គាត់។

ក្នុងឆ្នាំ១៩៥០ គាត់បានចូលក្នុងបក្សកុម្មុយនីស្តថៃ។ ពេលនោះហើយដែលគាត់បានទៅប្រទេសកម្ពុជាដើម្បីធ្វើសកម្មភាពដោយមានការគាំទ្រពីបក្សនៅប្រទេសថៃ។ គាត់បានធ្វើការឃោសនានយោបាយដល់ប្រជាជនដែលបានធ្វើបាបដោយបារាំង។

បន្ទាប់មក នួន ជា បានបញ្ជាក់ថា គាត់បានដឹងថាចលនាកុម្មុយនីស្តនៅកម្ពុជានៅពេលនោះត្រូវបានបង្កើតនិងគ្រប់គ្រងដោយវៀតណាម។ គាត់ត្រូវបានជ្រើសរើសដោយបក្សដើម្បីទៅសិក្សានៅវៀតណាមខាងជើង ប៉ុន្តែគាត់ចាប់ផ្តើមអស់ទំនុកចិត្តជាមួយបក្សដោយសារកុម្មុយនីស្តកម្ពុជា គឺជាអាយ៉ងរបស់វៀតណាម និងមិនមានភាពឯករាជ្យទេ។

ការគ្រប់គ្រងដោយវៀតណាមនៅតែបន្តទៀត ក្រោយពីឯករាជ្យពីប្រទេសបារាំងត្រូវបានទទួលស្គាល់ដោយសន្និសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៥៤។ នួន ជា បាននិយាយថា «គ្រាប់ពូជនៃការ

តស៊ូលែងមានទៀតហើយ» ។ នៅពេលដែល នួន ជា ត្រលប់ទៅប្រទេសកម្ពុជាវិញទៅពេលនោះ គាត់បានឃើញអ្វីៗគ្រប់យ៉ាងទាំងអស់ត្រូវបានគ្រប់គ្រងដោយវៀតណាម ហើយប្រជាជនកម្ពុជាធ្វើគ្រាន់តែជាអ្នកនាំសារ និងកូនទាហានតូចតាចប៉ុណ្ណោះ ។ មានខ្មែរតិចតួចប៉ុណ្ណោះបានធ្វើជាមេបញ្ជាការតែនោះ«គ្រាន់តែ»ជាអាយ៉ងរបស់វៀតណាមប៉ុណ្ណោះ ។ បក្សកុម្មុយនីស្តដែលចាប់កំណើតឡើងនៅកម្ពុជានៅពេលនោះគឺវៀតណាមជាអ្នកបង្កើតមិនមែន«ខ្មែរសុទ្ធ»ទេ ។

ពេល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ព្រះអង្គបានអំពាវនាវឲ្យប្រជាជនកម្ពុជាទាំងអស់រត់ចូលព្រៃ ។ នួន ជា បានអះអាងថា «ពេលនោះអ្នកល្អនិងអ្នកអាក្រក់សុទ្ធតែចូលព្រៃទាំងអស់ ។ ខ្លះគឺជាចោរប្លន់តែអ្នកនោះចូលជាមួយយើងដែរ ។ អ្នកនោះចាប់និងសម្លាប់ប្រជាជនកម្ពុជា ហើយបានទម្លាក់បក្សកុម្មុយនីស្តកម្ពុជា» ។ នួន ជា បានអះអាងថា នេះហើយដែលធ្វើឲ្យស្ថានភាពមានការប្របូកប្របល់ ។

មុននិងបញ្ចប់ នួន ជា បានបន្តអះអាងថា ចលនាកុម្មុយនីស្តដែលបង្ករឲ្យមានឧក្រិដ្ឋកម្មសង្គ្រាមនៅសវនការនេះគឺមិនមែនដឹកនាំដោយខ្មែរទេ គឺមកពីវៀតណាមដែលគ្រប់គ្រងបក្សនៅពេលនោះ ។ នួន ជា បានអះអាងថា «វៀតណាមគឺជាអ្នកសម្លាប់ប្រជាជនកម្ពុជា ។ ខ្ញុំមិនចង់ឲ្យក្មេងជំនាន់ក្រោយយល់ខុសពីប្រវត្តិសាស្ត្រទេ ។ ខ្ញុំក៏មិនចង់ឲ្យក្មេងជំនាន់ក្រោយគិតថា ខ្មែរក្រហមជាឧក្រិដ្ឋជនទេ ។ រឿងនេះមិនពិតទេ» ។

ខណៈពេលដែលអ្នកតាមដានដំណើរការគ្រវីក្បាល និងនិយាយខ្សឹបខ្សៀវៗគ្នា នួន ជា អះអាងបន្ថែមទៀតថា អ្វីៗទាំងអស់ដែលបានចោទប្រកាន់នៅក្នុងតុលាការនេះសុទ្ធតែខុសទាំងអស់ ។ នួន ជា បញ្ជាក់ថា «តុលាការមើលឃើញសត្រូវទៅជាមិត្តទៅវិញ» ហើយនេះគឺជាស្វាលាបមាត់ពពែ «ថ្ងៃណាមួយ យើងទាំងអស់គ្នានិងក្លាយជាចំណីរបស់ពស់ថ្លាន់» ។ នួន ជា បានប្រកាសនៅចំពោះមុខព្រះសង្ឃជាសាក្សីថា ការចោទប្រកាន់មកលើគាត់គឺមិនត្រឹមត្រូវទេ ព្រោះគាត់បានបូជាអាយុជីវិតរបស់គាត់ដើម្បីការពារប្រទេសជាតិ ។

ចៅក្រម និល ណុន បានថ្លែងអំណរគុណដល់ នួន ជា នូវអ្វីដែលគាត់បាននិយាយ ហើយគាត់ក៏បានបង្គាប់តុលាការឲ្យសម្រាក ។

## ដំណាក់កាលចុងក្រោយនៃទម្រង់ការនិតិវិធី

ក្រោយពីត្រលប់មកពីសម្រាកវិញ អង្គសវនាការបានចំណាយពេលមួយសន្ទុះដើម្បីធ្វើការទាក់ទងទៅនិងនិតិវិធីមួយចំនួនដែលបានលើកឡើង ។ ទីមួយគឺមេធាវីអន្តរជាតិមួយរូបបានចូលក្នុងក្រុមការពារក្តីរបស់ ខៀវ សំផន ដែរ ហើយក៏ត្រូវបានទទួលស្គាល់ដោយតុលាការនៅពេលនោះដែរ ។ ទីពីរ

គឺសហព្រះរាជអាជ្ញាបានកត់សម្គាល់ឃើញថា នួន ជា បាននិយាយអំពីកម្រងកំណត់ហេតុពណ៌ខៀវ ពេលដែលព្រះរាជអាជ្ញារូបនោះបានធ្វើការផ្ដល់យោបល់កាលពីព្រឹកមិញ ។ ដូចគ្នាទៅនឹងមន្ត្រីផ្នែកច្បាប់ជាន់ខ្ពស់ម្នាក់ដែរ សហព្រះរាជអាជ្ញាបានស្នើរសុំឯកសារកំណត់ហេតុនោះចែកចាយដល់ភាគីដទៃទៀតដែរ ។ ដោយកត់សម្គាល់ឃើញថា ឯកសារកំណត់ហេតុនោះត្រូវបានសរសេរដោយដៃហើយត្រូវបានតម្កល់ទុកក្នុងសំណុំឯកសាររួចហើយ មេធាវីរបស់ នួន ជា បានយល់ព្រមចែកចាយឯកសារនោះដល់ភាគីផ្សេងទៀតដែរ ។

ក្រោយមក ចៅក្រម និល ណុន បានប្រកាសពីសេចក្ដីសម្រេចរបស់តុលាការទាក់ទងទៅនឹងសំណើពីក្រុមមេធាវីរបស់ អៀង សារី ក្នុងការមិនបញ្ចូលឈ្មោះសាក្សីនិងភាគីដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីធ្វើសក្ខីកម្ម ។ ដោយបញ្ជាក់សារឡើងវិញថា ច្បាប់ក្នុងស្រុកមិនអាចយកមកអនុវត្តក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានទាំងស្រុងទេនោះ និល ណុន បានសំអាងទៅលើវិធានផ្ទៃក្នុង ៨៨ស្ទួនពីរ ដែលបញ្ជាក់ថា អ្នកជំនាញ និងសាក្សីនិងអង្គុយក្នុងទីដាច់ដោយឡែកពីគ្នា «ពេលណាដែលអាច» និងពេលនៅក្នុងបន្ទប់ អ្នកទាំងពីរមិនអាចនិយាយគ្នានិងទាក់ទងគ្នាបានទេ ។ អង្គសវនាការនិង«ធ្វើអស់ពីសមត្ថភាព»ដើម្បីធ្វើឲ្យប្រាកដថា វិធាននេះត្រូវបានប្រកាន់ភ្ជាប់ ហើយនិងធ្វើការជាមួយអង្គភាពគាំពារសាក្សីនិងអ្នកជំនាញដើម្បីប្រកាន់គោលជំហររបស់អង្គសវនាការនេះ ។ ទាក់ទងទៅនឹងភាគីដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទាំងនោះមានសិទ្ធនិងអង្គុយនៅក្នុងអង្គសវនាការពេញដំណើរការនេះដោយសារតែដើមបណ្ដឹងរដ្ឋប្បវេណីក៏ជាភាគីមួយដែរ ។ តែ និល ណុន បានបកស្រាយថា សវនាការនេះគឺជាសាធារណៈ នរណាដែលមានបំណងចង់តាមដានដំណើរការនេះ ក៏អាចធ្វើបានដែរ ។

ក្រោយមក ចៅក្រម ខាត់ព្រាយតី បាននិយាយពីសេចក្ដីសម្រេចរបស់តុលាការទាក់ទងទៅនឹងសំណើដែលធ្វើឡើងដោយក្រុមការពារក្ដីរបស់ នួន ជា កាលពីព្រឹកមិញ ។ ដំបូង ទាក់ទងទៅនឹងឯកសារនៅក្នុងដីការដំណោះស្រាយ និងនៅក្នុងឯកសារយោង ចៅក្រម ខាត់ព្រាយតី បានទាញចំណាប់អារម្មណ៍ដល់គ្រប់ភាគីទាំងអស់ឲ្យមើលអនុស្សារណៈរបស់តុលាការកាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ ដោយបញ្ជាក់ថា ឯកសារទាំងនេះនិងត្រូវយកមកដាក់នៅពីមុខតុលាការ«លុះត្រាតែមានការប្រកែកគ្នាមិនយល់ព្រម»ណាមួយ ។ បើសិនជាភាគីណាមួយមិនស្របទៅនឹងឯកសារណាមួយអង្គជំនុំជម្រះនិងធានាថា និងផ្ដល់ពេលវេលានៅក្នុងសវនាការដើម្បីតវ៉ាពីបញ្ហានេះ ។

បញ្ហាទីពីរគឺ ទាក់ទងទៅនឹងការបង្ហាញពីសេចក្ដីថ្លែងការណ៍កាលពីលើកមុនទៅកាន់សាក្សី ។ ចៅក្រម ខាត់ព្រាយតី បានបញ្ជាក់សារឡើងវិញថា ការផ្ដល់ឲ្យនេះគឺមិនអាចធ្វើឲ្យសាក្សីនឹកឃើញរឿងរ៉ាវ

របស់ខ្លួនល្អទេ ។ សេចក្តីថ្លែងការណ៍មុនៗ មិនគួរយកមកប្រើនៅក្នុងតុលាការទៀតទេ ហើយនិងត្រូវយកមកវិញភ្លាមក្រោយពីសាក្សីអានចប់ហើយ ។

មេធាវីរបស់ ខៀវ សំផន បានស្នើរឲ្យមានការបញ្ជាក់ឲ្យច្បាស់ទាក់ទងទៅនិងសេចក្តីសម្រេចរបស់ចៅក្រម និល ណុន ដោយបញ្ជាក់ថា ការបកប្រែជាភាសាបារាំងនៃសេចក្តីថ្លែងការណ៍នេះហាក់បីដូចជាថា ចៅក្រមជាអ្នកផ្តល់សិទ្ធឲ្យសាក្សីក្នុងការចូលរួមក្នុងដំណើរការមុននិងសាក្សីចូលមកធ្វើសក្ខីកម្ម ។ ពេលនោះចៅក្រម និល ណុន បានឆ្លើយតបទៅវិញថា ដោយសារតែសវនាការនេះមានលក្ខណៈសាធារណៈសមត្ថភាពរបស់សាក្សី និងអ្នកជំនាញក្នុងការតាមដានដំណើរការនេះ ពេលខ្លះហួសពីសមត្ថភាពរបស់តុលាការ ។ និល ណុន បានបញ្ជាក់ដែរថា តែអង្គភាពគាំពារសាក្សីនិងអ្នកជំនាញនិងត្រូវបានសួរដើម្បីជួយឲ្យបានច្រើនតាមតែអាចធ្វើទៅបាន ដោយលើកទឹកចិត្តសាក្សីដើម្បីធ្វើឲ្យការចងចាំមានភាពរស់រវើកឡើងវិញមុននិងធ្វើសក្ខីកម្ម ។

ក្រោយមក ចៅក្រម ឡាវ៉ែរ៉ាញ បានបកស្រាយនិងបញ្ជាក់ឲ្យច្បាស់ទៅនិងអ្វីដែលចៅក្រម និល ណុន បាននិយាយរួចហើយ ។ ចៅក្រម ឡាវ៉ែរ៉ាញ បានបញ្ជាក់ថា មនុស្សជាង៥០០នាក់អាចចូលរួមក្នុងដំណើរការកាត់ទោសនេះក្នុងមួយថ្ងៃ ហើយមានការលំបាកណាស់ក្នុងការត្រួតពិនិត្យមើលអ្នកដែលមកមើលទាំងអស់នេះ ។

## ការសួរសំនួរទៅកាន់ នួន ជា បន្តទៀត

ក្រោយពីបញ្ចប់និតិវិធីមួយចំនួនមក ចៅក្រម ខាត់ព្រ៊ាយត៍ បានបន្តសួរ នួន ជា ទៀត ។ ដោយមើលឯកសារដែលបានរៀបរាប់នៅក្នុងដីការដំណោះស្រាយ និងតាមសេចក្តីថ្លែងការណ៍របស់ នួន ជា ចៅក្រម ខាត់ព្រ៊ាយត៍ បានសួរទៅ នួន ជា នូវសំនួរមួយចំនួនដើម្បីសុំបញ្ជាក់ឲ្យច្បាស់ថែមទៀតទាកទងទៅនិងប្រវត្តិចលនាកុម្មុយនីស្តកម្ពុជា សមាជិកភាពនិងតួនាទីរបស់ជនជាប់ចោទរូបនេះនៅក្នុងចលនាកុម្មុយនីស្ត ។ នួន ជា បានឆ្លើយគ្រប់សំនួរទាំងអស់ដែលបានចោទសួរមកលើគាត់ តែគាត់បានឆ្លើយដោយយឺតៗ ។

នួន ជា បានឆ្លើយថា ពេលដែលគាត់បានមកដល់ប្រទេសកម្ពុជាក្នុងឆ្នាំ១៩៥១ គាត់ត្រូវបានបញ្ចុះបញ្ចូលឲ្យចូលក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិន ដែលជាគោលការណ៍របស់បក្សដែលបានចែងថាអ្នកដែលចង់ធ្វើសកម្មភាពកុម្មុយនីស្តត្រូវតែចូលក្នុងបក្សនៅក្នុងប្រទេសនោះ ។ ក្នុងឆ្នាំ១៩៥១ វៀតណាមបានបែងចែកបក្សកុម្មុយនីស្តឥណ្ឌូចិនជាបីបក្ស មួយនៅប្រទេសវៀតណាម មួយនៅកម្ពុជានិងមួយទៀតនៅប្រទេសឡាវ ។ នួន ជា បានបញ្ជាក់ទៀតថា វៀតណាមសម្រេចដូច្នេះដោយសារតែដឹងថា កម្ពុជានិងមិនទទួលយកគោលការណ៍របស់បក្សកុម្មុយនីស្តឥណ្ឌូចិនដែលធ្លាប់មានពីមុនទេ ។ ប៉ុន្តែ

ទោះបីជាបក្សនេះមានបីដាច់ពីគ្នាក៏ដោយ ក៏គ្មានបក្សណាមួយមានភាពឯករាជ្យដែរ ។ បក្សទាំងអស់គឺក្រោមការគ្រប់គ្រងរបស់វៀតណាម ។

ឆ្លើយទៅនិងសំនួរមួយថា តើបក្សពលករខ្មែរគឺជារបស់ "បក្សកុម្មុយនីស្តខ្មែរសុទ្ធសាទតំបូងគេ" ឬយ៉ាងណា នួន ជា បានបញ្ជាក់ថា ក្នុងឆ្នាំ១៩៦០ មនុស្សមួយចំនួននៅក្នុងបក្សប្រជាជនបដិវត្តខ្មែរមើលឃើញថា ប្រជាជនកម្ពុជាជាច្រើនចង់បាន "ឯករាជ្យពីការគ្រប់គ្រងរបស់វៀតណាម" ។ អ្នកទាំងនោះ រួមមាន ទូ សាមុត (នួន ជា ហៅថា លោកតា ទូ សាមុត) ដែលបានសម្រេចរៀបចំបក្សក្នុងជួរបក្សលក្ខន្តិកៈ និងយុទ្ធសាស្ត្ររបស់ខ្លួន ដែលបង្កើតឲ្យមានការបង្កើតបក្សពលករខ្មែរ ។ នួន ជា បានបញ្ជាក់ថា វៀតណាមមិនបានគាំទ្របក្សថ្មីនេះទេ ហើយមានបំណងចង់រំលាយបក្សនេះចោល ។ នួន ជា និយាយថា វៀតណាមចង់បំបែកបក្សនេះពីខាងក្នុងដោយបញ្ចុះបញ្ចូលបក្សដោយសម្ងាត់ដើម្បីគ្រប់គ្រងបក្សនេះទាំងមូលវិញ ។ ដោយបានអះអាងម្តងទៀតដើម្បី "លាតត្រដាងអំពីមហិច្ឆតារបស់វៀតណាមដើម្បីលេប ទឹកដីកម្ពុជា" នួន ជា បានប្រាប់ទៅចៅក្រមម្តងទៀតនូវអ្វីដែលខ្លួនបានរៀបរាប់នៅក្នុងសេចក្តីថ្លែងការណ៍ បើកដោយសំអាងថា វៀងណាមចង់បានដីបន្តបង្កើនផលចំនួនបីលានហិចតាថា "ឆ្ងាញ់ណាស់" ។

នួន ជា បានបញ្ជាក់ថា បក្សពលករខ្មែរត្រូវបានដូរឈ្មោះទៅជាបក្សកុម្មុយនីស្តកម្ពុជាក្នុងឆ្នាំ ១៩៦០ដើម្បីគម្លាតពីបក្សរបស់វៀតណាមនិងចិន ដែលនៅប្រើពាក្យ "បក្សពលករ" ដែរ ។ បក្សថ្មីនេះគឺដូរត្រឹមតែឈ្មោះតែប៉ុណ្ណោះ តែមាគ៌ារបស់បក្សនៅដដែល ។ ទាក់ទងទៅនិងតួនាទីនៅក្នុងបក្សនេះ នួន ជា បានសារភាពថា គាត់គឺជាលេខាបក្សប្រជាជនបដិវត្តខ្មែរ បក្សពលករខ្មែរ និងបក្សកុម្មុយនីស្តកម្ពុជា ។

នៅពេលសួរថាតើមានដឹងពីការបាត់ខ្លួនរបស់ ទូ សាមុត ដែរឬទេក្នុងឆ្នាំ១៩៦២ នួន ជា បានឆ្លើយថា គាត់បានទៅផ្ទះ ទូ សាមុត ហើយបានសួរទៅប្រពន្ធរបស់គាត់ថា តើ ទូ សាមុត ទៅណា? នៅពេលដែលប្រពន្ធរបស់ ទូ សាមុត ប្រាប់ថា គាត់បានទៅផ្សាយូរហើយ តែមិនទាន់ត្រលប់មកវិញទេ ពេលនោះ នួន ជា បានមានការសង្ស័យរួចទៅហើយថា ទូ សាមុត ពិតជាមានគ្រោះថ្នាក់ចរាចណ៍ឬត្រូវបានចាប់ខ្លួនជាមិនខាន ។ ភ្លាមនោះ នួន ជា បានទៅជួយ សាឡុត ស ហៅ ប៉ុល ពត ដើម្បីសុំដំបូន្មាន ពីគាត់ដើម្បីចាត់វិធានការ ។ នួន ជា បានបញ្ជាក់ថា តាមគោលការណ៍បក្ស ផ្ទះរបស់អ្នកដែលត្រូវបានចាប់ខ្លួនត្រូវតែទុកនៅទំនេ ។ ពីរបីថ្ងៃក្រោយមក យោធាដែលជាខ្សែទាក់ទងរបស់ សាឡុត ស បានជូនដំណឹងមក សាឡុត ស ថា មេដឹកនាំខ្មែរក្រហមសំខាន់ម្នាក់ត្រូវបានចាប់ខ្លួនធ្វើទារុណកម្ម និងសម្លាប់នៅវត្តមួយ ។ ពេលនោះ នួន ជា គិតថា អ្នកនោះគឺជា ទូ សាមុត ។

បន្ទាប់ពី នួន ជា បញ្ចប់ការឆ្លើយតបរបស់ខ្លួន អង្គសវនាការដល់ម៉ោងសម្រាក ។

ពេលចូលក្នុងបន្ទប់សវនាការវិញ នួន ជា បានស្នើរទៅតុលាការឲ្យបញ្ចប់ការសួរ នាំរូបគាត់នៅពេលនេះដោយសារតែ“គាត់មិនសូវស្រួលខ្លួន” ។ ក្រោយពីពិភាក្សាជាមួយចៅក្រមផ្សេងទៀតរួចមកប្រធានចៅក្រម និល ណុន បានឲ្យ នួន ជា “បន្តនិយាយយឺតៗ” ដែលធ្វើឲ្យអ្នកតាមដានដំណើរការសើច ។ ពេលនោះ នួន ជា សុំសម្រាកម្តងទៀត ហើយអង្គសវនាការបានឆ្លើយថានិងបន្តដំណើរការទៅមុខរយៈកន្លះម៉ោងទៀត ។

ចៅក្រម ខាត់វ្រាយត៍ បានត្រលប់មកសួរសំនួរទៀតអំពីការបាត់ខ្លួន ទូ សាមុត ដោយសួរថាតើគ្រួសាររបស់ ទូ សាមុត ត្រូវបាននាំទៅរស់នៅកន្លែងសុវត្ថិភាពឬអត់ ហើយលោកស្រីចៅក្រមបានលើកទឹកចិត្តឲ្យ នួន ជា ប្រាប់រឿងរ៉ាវនោះម្តងទៀតអំពីការបាត់ខ្លួនរបស់ ទូ សាមុត ។

ចៅក្រម ខាត់វ្រាយត៍ បានសួរអំពីការដែល នួន ជា ទៅទទួលការបណ្តុះបណ្តាលនៅវៀតណាម ។ នួន ជា បានឆ្លើយថា គាត់បានទទួលការអប់រំនយោបាយអស់រយៈពេលជាងមួយឆ្នាំ តែគាត់មិនបានចូលរួមក្នុងដំណើរការនេះពេញលេញទេ ។ គាត់បដិសេធថា គាត់មិនបានចូលរួមបណ្តុះបណ្តាលផ្នែកយោធាណាមួយទេ ទោះនៅវៀតណាមក្តី ឬនៅកម្ពុជាក្តី ។

ពេលដែល ចៅក្រម ខាត់វ្រាយត៍ ចាប់ផ្តើមសួរអំពី“អង្គការការពារសម្ងាត់”របស់បក្ស នួន ជា ឈប់ឆ្លើយហើយសុំសម្រាក់សម្រាប់ថ្ងៃនេះ ។

ក្រោយពីពិភាក្សាគ្នារួចមក ចៅក្រម និល ណុន បានប្រកាសថា ដោយសារតែជនជាប់ចោទបានសហការល្អជាមួយអង្គជំនុំជម្រះ ហើយតុលាការបានសួរសំនួរជាច្រើនមកហើយ តុលាការយល់ព្រមទៅនឹងសំណើរនេះ ។ អង្គសវនាការបានបញ្ចប់នៅថ្ងៃនេះ ហើយនិងបន្តសួទៅកាន់ នួន ជា នៅថ្ងៃស្អែកទៀត ។

**-ចប់-**